ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ១៣០៥
ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០
សាលក្រមលេខ៖ ១៥១ "ក១"
ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

-បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នាថ្ងៃពុធ ១៤កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១ ដោយមាន៖

**ដោយមានសមាសភាពដូចតទៅ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទឈ្មោះ [redacted] **ពុធមិសាល** អាសយដ្ឋានបច្ចុប្បន្ន [redacted] ។

មេធាវីតំណាងដោយអាណត្តិអោយដើមចោទ៖ [redacted] **ហៃ** និង [redacted] **សារិទ្ធិ** អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ [redacted]។

សហចុងចម្លើយឈ្មោះ [redacted] **ហឿន** ភេទប្រុស, ឈ្មោះ [redacted] **ចាន់សាវី** ,ឈ្មោះ [redacted] **វិបុល** ភេទប្រុស អាសយដ្ឋានបច្ចុប្បន្ន [redacted]។

## I. អង្គហេតុ និងចំណុចវិវាទ

### ១.ខ្លឹមសារនៃសាលក្រមដែលភាគីទាមទារឲ្យតុលាការចេញ

**១.១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

-សុំអោយចុងចម្លើយសងប្រាក់ដើមចំនួន USD ១៣.០០០ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក

-សុំសងការប្រាក់តាមច្បាប់កំណត់ គិតចាប់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសំណងជម្ងឺចិត្ត ចំនួន USD ៣០០០ (បីពាន់)ដុល្លារអាមេរិក

-សុំអោយអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម

-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

**១.២ ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយទាមទារឲ្យតុលាការចេញ៖**

-គ្មាន ។

### ២. ការសង្ខេបអំពីរឿងក្តី

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ សហចុងចម្លើយឈ្មោះ [redacted] ហឿន ,[redacted] វិបុល,[redacted] ចាន់សាវី បានខ្ចីប្រាក់ពីដើមចោទចំនួន USD ២០.០០០ (ពីរម៉ឺន ដុល្លារអាមេរិក) ដូចមានក្នុងកិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ ដោយមានភ្ជាប់ជាមួយការប្រាក់នោះទេ ហើយសហចុងចម្លើយសន្យាថានឹងសងវិញក្នុងរយៈពេលពីរខែកន្លះគិតពីថ្ងៃផ្តិតមេដៃ ។ នៅឆ្នាំ២០១៩

សហចុងចម្លើយបានសងប្រាក់មកដើមចោទបានចំនួន USD ៧០០០ (ប្រាំពីរពាន់ ដុល្លារអាមេរិក) ចំណែកឯប្រាក់ជំពាក់នៅសល់ចំនួន USD ១៣.០០០ (មួយម៉ឺន បីពាន់ ដុល្លារអាមេរិក) សហចុងចម្លើយមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនទេ ទោះបីជាដើមចោទបានដាស់តឿនក៏ដោយ ទើបដើមចោទដាក់ពាក្យប្តឹងមកតុលាការឱ្យចេញសាលក្រម ។

## ៣.អង្គហេតុដែលអះអាងដោយដើមចោទ

លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិ កូនក្តីខ្លួនបានដាក់ពាក្យបណ្តឹងចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ដែលមានខ្លឹមសារនៃការទាមទារ៖

១.សុំអោយចុងចម្លើយសងប្រាក់ដើមចំនួន USD ១៣.០០០ (មួយម៉ឺនបីពាន់)ដុល្លារអាមេរិក

២.សុំសងការប្រាក់តាមច្បាប់កំណត់ គិតចាប់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសំណងជម្ងឺចិត្តចំនួន USD ៣០០០ (បីពាន់)ដុល្លារអាមេរិក

៣.សុំអោយអនុវត្តសាលក្រមជាបណ្តោះអាសន្នលើប្រាក់ដើម

៤.ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ ។

មូលហេតុនៃការប្តឹងសុំគឺ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ ចុងចម្លើយឈ្មោះ [redacted] ហឿន (ស្លាប់) , [redacted] វិបុល និងឈ្មោះ [redacted] ចាន់សាវី បានខ្ចីប្រាក់ពីកូនក្តីខ្លួនចំនួន USD ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដូចមានកិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ ដោយមិនបានគិតការប្រាក់នោះទេ តែត្រូវសងប្រាក់នេះមកកូនក្តីខ្លួនវិញក្នុងរយៈពេល០២ខែកន្លះ គិតពីថ្ងៃផ្តិតមេដៃខ្ចីប្រាក់ ។ លុះដល់ការកំណត់សងចុងចម្លើយមិនបានសងប្រាក់មកកូនក្តីខ្លួនទេ ។ នៅអំឡុងឆ្នាំ២០១៩ ចុងចម្លើយបានសងប្រាក់មកកូនក្តីខ្លួនចំនួន USD ៧០០០ (ប្រាំពីរពាន់ដុល្លារអាមេរិក) នៅសល់ USD ១៣.០០០ (មួយម៉ឺនបីពាន់ដុល្លារអាមេរិក) ចុងចម្លើយនៅមិនទាន់បានសងមកកូនក្តីខ្លួនទេ ទោះបីជាកូនក្តីខ្លួនដាស់តឿនក្នុងការសងច្រើនដងក៏ដោយ តែចុងចម្លើយនៅតែមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ។ ទើបកូនក្តីខ្លួនដាក់ពាក្យបណ្តឹងមកតុលាការ អោយតុលាការចេញសាលក្រមតាមការទាមទារ ។ ចំពោះការប្រាក់កូនក្តីខ្លួនស្នើសុំអោយចុងចម្លើយសងការប្រាក់តាមច្បាប់កំណត់លើទឹកប្រាក់ដើមដែលនៅសល់ចំនួន USD ១៣.០០០ (មួយម៉ឺនបីពាន់ដុល្លារអាមេរិក) គិតចាប់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ចំនួន រីឯការទាមទារជម្ងឺចិត្តចំនួន USD ៣០០០ (បីពាន់ដុល្លារអាមេរិក) កូនក្តីខ្លួនមិនទាមទារទេ ។ ហេតុនេះសុំតុលាការសម្រេចចេញសាលក្រមតាមការទាមទារ និងស្នើសុំអោយសាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ។

## ៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ

ចុងចម្លើយឈ្មោះ [redacted] **វិបុល** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនគឺជាតំណាង [redacted] ហឿន និងឈ្មោះ [redacted] ចាន់សាវី ព្រោះម្តាយខ្លួនឈឺ។ ខ្លួនទទួលស្គាល់ចំពោះពាក្យបណ្តឹងដែលដើមចោទទាមទារខ្លួនចំនួន USD ១៣.០០០ (មួយម៉ឺនបីពាន់ដុល្លារអាមេរិក) ចំពោះការប្រាក់ខ្លួនសុំបដិសេធ ព្រោះក្នុងកិច្ចសន្យាមិនបានចែងនោះទេ ។ ការទាមទារត្រង់ចំណុចការប្រកាសអនុវត្តបណ្តោះអាសន្ន និងប្រាក់ប្រដាប់ក្តី សុំអោយតុលាការសម្រេចតាមច្បាប់ ។ មូលហេតុដែលខ្លួនសុំបដិសេធការទាមទារការប្រាក់ព្រោះពេលធ្វើកិច្ចសន្យាឪពុករបស់ខ្លួន និងដើមចោទបានឯកភាពគ្នាមិនគិតការប្រាក់នោះទេ ។ ចំពោះប្រាក់ដើមដែលទទួលស្គាល់គឺ ខ្លួនសុំសងប្រាក់ចំនួន USD ២០០ (ពីររយ)ដុល្លារអាមេរិក ហើយក្នុងអំឡុងពេល០៥ខែសុំសងរំលួសប្រាក់ដើមចំនួន USD ១០០០ ឬ USD ២០០០ ទៅដើមចោទ ។

## ៥.ចំណុចវិវាទ

-តើការទាមទារការប្រាក់,និងការស្នើសុំប្រកាសសាលក្រមអនុវត្តជាបណ្តោះអាសន្ន របស់ដើមចោទត្រឹមត្រូវដែរឬទេ? ៚



Scanned with CamScanner

## ៦.ចំណុចគ្មានវិវាទ

-ដើមចោទទាមទារប្រាក់ដើមចំនួន USD ១៣.០០០ (មួយម៉ឺន បីពាន់ ដុល្លារអាមេរិក) ហើយចុងចម្លើយក៏ទទួលស្គាល់ការទាមទារនេះ ។

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ**

-កិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

-គ្មាន ។

## សំអាងហេតុ

ឆ្លងតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងនានា យល់ឃើញថា៖

**១.ការវិនិច្ឆ័យអំពីចំនួនទឹកប្រាក់ដែលបានទទួលស្គាល់**

ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ នៃរឿងក្តីនេះ សហចុងចម្លើយឈ្មោះ[redacted] ហឿន ភេទប្រុស, ឈ្មោះ[redacted]ចាន់សារី ,ឈ្មោះ [redacted] វិបុល ខ្ចីប្រាក់ពីដើមចំនួន USD ២០០០០ (ពីរម៉ឺន)ដុល្លារអាមេរិក រយៈពេលខ្ចីចំនួន ពីរខែកន្លះ ។ តាមការអះអាងក្នុងសេចក្តីថ្លែងការណ៍របស់លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទថា សហចុងចម្លើយបានសងប្រាក់អោយដើមចោទចំនួន USD ៧០០០ (ពីរពាន់ដុល្លារអាមេរិក) ។ សហចុងចម្លើយនៅ ជំពាក់ប្រាក់ដើមចោទចំនួន USD ១៣ ០០០ (មួយម៉ឺន បីពាន់ ដុល្លារអាមេរិក) ទៀតមិនព្រមសង ។ សហចុងចម្លើយឈ្មោះ [redacted] វិបុល បានអះអាងតំណាងអោយសហចុងចម្លើយឈ្មោះ[redacted]ហឿន និងឈ្មោះ[redacted] ចាន់សារី បានទទួលស្គាល់ថា ខ្លួននៅជំពាក់ប្រាក់របស់ដើមចោទចំនួន USD ១៣ ០០០ (មួយម៉ឺនបីពាន់ ដុល្លារអាមេរិក) ពិតប្រាកដមែន ។

**២.ស្តីពីចំណុចវិវាទអំពីការទាមទារការប្រាក់**

ដើមចោទទាមទារការប្រាក់តាមច្បាប់កំណត់ ចុងចម្លើយសុំបដិសេធការទាមទារការប្រាក់ពីព្រោះក្នុងកិច្ចសន្យាខ្ចីប្រាក់មិនបានគិតការប្រាក់ទេ ។ ចំណុចនេះតុលាការយល់ឃើញថា ការទាមទារការប្រាក់ របស់ដើមចោទ ជាការទាមទារត្រឹមត្រូវតាមច្បាប់ ទោះបីកិច្ចសន្យាមិនបានចែងពីការប្រាក់ក៏ដោយ ដើមចោទអាចទាមទារការ ប្រាក់តាមច្បាប់បាន ផ្អែកតាមមាត្រា៥៨៣ នៃក្រមរដ្ឋប្បវេណី , តាមមាត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី និងតាមប្រកាសលេខ១២៨ កយប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ ដែលត្រូវបានកម្រិតដែលមិនអាចអោយលើសពី ១៨ % ក្នុងមួយឆ្នាំ ។

**៣.ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី**

នៅក្នុងរឿងក្តី ស្តីពីការទាមទារអោយសងប្រាក់កំចីនៃរឿងក្តីនេះ ចុងចម្លើយជាអ្នកចាញ់ក្តី ។ ហេតុនេះ តាមមាត្រា៦៤ នៃក្រមរដ្ឋប្បវេណី ចុងចម្លើយត្រូវទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី ។

**៤.ស្តីពីការប្រកាសអោយអនុវត្តជាបណ្តោះអាសន្ន**

ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ ហើយតុលាការទទួលស្គាល់ថា មានភាពចាំបាច់ ដូច្នេះប្រកាសអោយអនុវត្តជាបណ្តោះអាសន្នចំពោះសេចក្តីសម្រេចបញ្ចប់ខាងក្រោមត្រង់ចំណុចទី១ ផ្អែកតាមមាត្រា១៩៦នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ចំនួនប្រាក់ដែលត្រូវសងទៀតសោត ចុងចម្លើយបានទទួលស្គាល់ការជំពាក់ច្បាស់លាស់ ហេតុនេះបើមានបណ្តឹងឧបាស្រ័យ ក៏តុលាការជាន់ខ្ពស់មុខជាមិនបដិសេធនោះដែរ ។

<u>សេចក្តីសម្រេចបញ្ចប់</u>

**១**-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ចំនួន USD ១៣.០០០ (មួយម៉ឺនបីពាន់ ដុល្លារអាមេរិក) ទៅឱ្យដើមចោទឈ្មោះ [redacted] **ពុធមិសាល** ដែលមានលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

២.បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន USD ១៣.០០០ (មួយម៉ឺន បីពាន់) ដុល្លារអាមេរិក គិតចាប់ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧ រហូតដល់ថ្ងៃសងគ្រប់ចំនួន ។

៣.ចំនុចទី១ នៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រមនេះ អាចអនុវត្តជាបណ្តោះអាសន្នបាន ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះបានប្រកាសជាសាធារណៈនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមនេះនេះ

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា ៖ [redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

"បានចម្លងចេញពីសាលក្រមដើមត្រឹមត្រូវហើយ"

ថ្ងៃព្រហស្បតិ៍០៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner